



១

# បទបង្ហាញ
# ស្ដីពី
## បទពិសោធន៍ក្នុងការអនុវត្តការងារភូមិ ឃុំ សង្កាត់មានសុវត្ថិភាព
## ក្នុងពិធីសន្និបាតបូកសរុបសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
## អាណត្តិទី៥ ២០២២ - ២០២៥

**លោកស្រី ស៊ុំ កល្យាណ មេឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល**

ថ្ងៃទី៧-៨ ខែកញ្ញា ឆ្នាំ២០២៦

# មាតិកា

1- សេចក្តីផ្តើម

2- ការគ្រប់គ្រង ការប្រើប្រាស់ថវិការបស់ឃុំឆ្នាំ២០២២-២០២៥

3 - ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព

4 - បទពិសោធន៍ល្អៗ ក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព

5 - បញ្ហាប្រឈម និងសំណូមពរ

## ១.សេចក្តីផ្តើម

### លក្ខណៈភូមិសាស្ត្រ

- **លក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ**

ឃុំដំណាក់អំពិល ជាឃុំមួយក្នុងចំណោមឃុំទាំង១០ក្នុងស្រុកអង្គស្នួល មានផ្ទៃដី ៩៣០ គម² មានផ្លូវជាតិភ្ជាប់ឆ្លងកាត់ចំនួន៣ខ្សែរ ៤, ៤១, និង ៥១។ ខាងកើតជាប់នឹងឃុំពើក ខាងត្បូងឃុំលំហាច ខាងជើងឃុំសំរោងលើ ខាងលិចជាប់ឃុំសំបូរ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។



- មាន១០ភូមិ មានប្រជាពលរដ្ឋសរុប៨,៤១៩នាក់ ស្មើនឹង២,១៤៤គ្រួសារ។

ស្នាក់នៅបណ្តោះអាសន្ន ៦៧៣ នាក់ ស្មើនឹង៩០ គ្រួសារ។

កម្លាំងអនុវត្ត៖ ក្រុមប្រឹក្សាឃុំ ៥ នាក់ ប៉ុស្តិ៍នគរបាល ៦ នាក់ ប្រជាការពារ ១២០ នាក់។ ជាតំបន់ទីប្រជុំជន មានផ្សារ និងរោងចក្រ។

ប្រកបមុខរបរភាគច្រើន៖ កម្មករ/សេវាកម្មសេដ្ឋកិច្ចក្រៅប្រព័ន្ធ ៧៥% និង កសិកម្ម ២៥%។



# ២.ការគ្រប់គ្រង ការប្រើប្រាស់ថវិការបស់ឃុំ២០២២.២០២៥

➤ ប្រភពថវិកា និងការចំណាយ

ប្រភពចំណូល៖ ផ្ទេរពី«ថវិកាជាតិ(មូលនិធិឃុំ-សង្កាត់)»បូករួម«កញ្ចប់អភិវឌ្ឍន៍បន្ថែម»និង«កម្រៃសេវារដ្ឋបាលប្រមូលបាន»។ មុខសញ្ញាចំណាយ៖ ចែកជា «ចំណាយប្រតិបត្តិការរដ្ឋបាល» (ប្រាក់ឧបត្ថម្ភ-សម្ភារៈ) និង «ចំណាយអភិវឌ្ឍន៍» (ជួសជុលផ្លូវបេតុងអាមេ)។ប្រកបដោយគណនេយ្យភាព & តម្លាភាព៖ ផែនការចេញពី «តម្រូវការប្រជាពលរដ្ឋ» អនុវត្ត «ដេញថ្លៃបើកចំហ» បិទផ្សាយតួលេខ និងទទួលការត្រួតពិនិត្យពីស្ថាប័នសវនកម្មជាតិជារៀងរាល់ឆ្នាំ។

៤

**តារាងថវិការបស់ឃុំដំណាក់អំពិល**

| ឆ្នាំ | ចំណូល | ចំណាយ | មុខសញ្ញាចំណាយ | |
|---|---|---|---|---|
| ២០២២ | ៧៥៧,៣៧០.៥៥៨៛ | ៦៤៨,៥៩៨,២០០៛ | អភិវឌ្ឍន៍៖ជួសជុលផ្លូវបេតុង | ២២០,០០០,០០០៛ |
| | | | រដ្ឋបាល៖ ប្រាក់ឧបត្ថម្ភ | ២៤២,០០០,០០០៛ |
| ២០២៣ | ៧២៤,០៨៧,៣៥៨៛ | ៦៧០,៣៥៣,៩៦៨៛ | អភិវឌ្ឍន៍៖ជួសជុលផ្លូវបេតុង | ២៧០,០០០,០០០៛ |
| | | | រដ្ឋបាល៖ប្រាក់ឧបត្ថម្ភ | ២៦៧,០០០,០០០៛ |
| ២០២៤ | ៧៨៤,២៩៣,៥៩០៛ | ៦៦៨,៤២៥,២៦៩៛ | អភិវឌ្ឍន៍៖ជួសជុលផ្លូវបេតុង | ៣០១,០០០,០០០៛ |
| | | | រដ្ឋបាល៖ប្រាក់ឧបត្ថម្ភ | ២៩៤,៩០០,០០០៛ |
| ២០២៥ | ៨៦៣,១៩៦,៣២១៛ | ៥៧៣,៦១៦,១០៧៛ | អភិវឌ្ឍន៍៖ជួសជុលផ្លូវបេតុង | ៣៧២,០០០,០០០៛ |
| | | | រដ្ឋបាល៖ប្រាក់ឧបត្ថម្ភ | ៣៧៤,៩០០,០០០៛ |






# ៣. ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព

លទ្ធផលការងារ "ភូមិ-ឃុំ សង្កាត់ មានសុវត្ថិភាព"  គឺបានមកពីការតម្រង់ទិសយ៉ាងមុតស្រួច ដោយមានការដឹកនាំពីគណៈបញ្ជាការឯកភាពខេត្តកណ្តាល គណៈបញ្ជាការឯកភាពស្រុក អង្គស្នួល ធ្វើឱ្យមូលដ្ឋានឃុំយើងខ្ញុំសម្រេចបាន៖



- **ទិន្នន័យនានាពាក់ព័ន្ធបទល្មើស**



- បទល្មើសគ្រឿងញៀនចំនួន២០ករណី ឃាត់ខ្លួនជនសង្ស័យ៣៥នាក់ បញ្ជូនទៅតុលាការ
- បទល្មើសព្រហ្មទណ្ឌចំនួន១២ករណីបង្ក្រាបបាន១២ករណី ក្មេងទំនើង៥ករណី
- ល្បែងស៊ីសង មានចំនួន២៥ករណី មនុស្ស៣១នាក់។

- **សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពចរាចរណ៍៖** ករណីកើតឡើងគ្រោះថ្នាក់ចរាចរណ៍ ២៨ ករណី  ស្លាប់១៧នាក់  របួស២៧នាក់ ខូចខាតមធ្យោបាយ៣២គ្រឿង (ម៉ូតូ ១៩, រ៉ឺម៉ក ១, រថយន្ត១២គ្រឿង)។ បានជួយសម្រួលចរាចរណ៍តំបន់កកស្ទះតាមសាលារៀន តំបន់ផ្សារ តំបន់រោងចក្រ។



# ៣. ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព(ត)

- **វិធានការបង្ការ និងទប់ស្កាត់ជាមុន មានដូចជា ការងារល្បាត និងទទួលព័ត៌មានពីប្រព័ន្ធឌីជីថល(គ្រុប)**

– ការចេញល្បាតរួមគ្នា៖ កម្លាំងនគរបាលប៉ុស្តិ៍ សហការជាមួយក្រុមប្រឹក្សាឃុំ ភូមិ ប្រជាការពារភូមិ ចុះល្បាតចល័តក្នុងមូលដ្ឋាន ជាប្រចាំ (ជាពិសេសពេលយប់) នៅតាមចំណុចប្រឈម នានាក្នុងមូលដ្ឋានឃុំ។

– យុទ្ធនាការផ្សព្វផ្សាយច្បាប់ គោលនយោបាយទូទាំងឃុំ៖

  - ផ្សព្វផ្សាយ គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពបានចំនួន ៧៦៨លើក មានប្រជាពលរដ្ឋចូលរួម ៣៨ ៤០០នាក់ ស្រី ២.១១៥០នាក់។
  - វេទិកាសាធារណៈ មានចំនួន ៦៤៨លើក អ្នកចូលរួម ១២. ៦៦០នាក់ ស្រី ៩. ១៥០នាក់។

៦

– យន្តការរាយការណ៍ព័ត៌មានរហ័ស (លឿន សម្ងាត់ ជឿជាក់) ៖ ប៉ុស្តិ៍រដ្ឋបាលចុះចែកលេខទូរស័ព្ទតាមខ្នងផ្ទះ លេខទូរស័ព្ទ Hotline របស់អធិការដ្ឋាននគរបាលស្រុក មានគ្រុប Telegram messenger App NoDurg (ក្រសួង) ដើម្បីឱ្យប្រជាពលរដ្ឋរាយការណ៍បទល្មើសភ្លាមៗ ។




– ការបង្រ្កាបបទល្មើសជាក់ស្តែង៖ ចុះអន្តរាគមន៍ និងឃាត់ខ្លួនជនល្មើសភ្លាមៗ ពេលមានករណី លួច ឆក់ ប្លន់ ហិង្សាក្នុងគ្រួសារ ក្មេងទំនើងដេញវាយគ្នា ជាដើម។

– ការចុះធ្វើវេទិកាសាធារណៈ៖ក៏បានទទួលព័ត៌មាន ពីបណ្តឹង ពីទុក្ខកង្វល់ បញ្ហាប្រឈម ដើម្បីស្រាវជ្រាវរកដំណោះស្រាយ។

## ៣. ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព(ត)

- ការរៀបចំសណ្តាប់ធ្នាប់នៅមុខផ្សារថ្នល់ទទឹងនិងតាមផ្លូវជាតិលេខ៤,៤១និង៥១
- យន្តការអនុវត្ត៖ សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលស្រុក អនុវត្តតាមសេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តកណ្តាល។

❖ **ការផ្សព្វផ្សាយ៖** ចែក និងផ្សព្វផ្សាយលិខិតជូនដំណឹងបាន២៣៥ ផ្ទះ និង ១៥៨តូប។ ការរុះរើ (កំណត់មុខសញ្ញាសរុប២១២)ផ្ទះ៥៥ តូបលក់ដូរ ១២៨ តូប

លទ្ធផលសម្រេចបាន៖ រុះរើបាន ផ្ទះ៣០ តូប៩២ និងកំពុងបន្តរុះរើបន្ថែម។

❖ **ចលនាប្រជាការពារ**

ការចលនាប្រជាការពារ គឺជាការប្រមូលផ្តុំកម្លាំងស្ម័គ្រចិត្តក្នុងមូលដ្ឋាន ឱ្យចូលរួមសហការជាមួយនគរបាល ចុះល្បាត ការពារសន្តិសុខ សណ្តាប់ធ្នាប់ ការងារបរិស្ថាន និងការងារសង្គម។





❖ ***ការចូលរួមពី ថ្នាក់ដឹកនាំ & ការកៀរគរសប្បុរសជននានា***

ប៉ុស្តិ៍ប្រជាការពារ៥កន្លែង៖ ប្រើថវិកា៥,៥០០$ ប្រចាំការ ២៤ម៉ោង មាន៥កន្លែង ឡានសារ៉ែន១គ្រឿង ៤,៥០០$ និងវិទ្យុទាក់ទង ៨៨គ្រឿង មានកាមេរ៉ាសុវត្ថិភាពសរុប ៨៩០គ្រាប់ បានដាក់បង្គោលសូឡា នៅទីកន្លែងប្រឈម តាមផ្លូវសាធារណៈ តាមខ្នងផ្ទះ ប្រើអំពូលសូឡាសរុប ១,២១៩ ដើម។

ឧបត្ថម្ភប្រជាការពារថវិកា ១៥ លានរៀល, អង្ករ ៤ តោន, ទឹកត្រី-ស៊ីអ៊ីវ ៨០០ យួរ និងអាវប្រជាការពារ ២២៥ អាវ។

៧








## ❑ លទ្ធផលនៃការផ្តល់សេវារដ្ឋបាល និងសេវាសាធារណៈ (២០២២ - ២០២៥)

### ១. ការផ្តល់សេវារដ្ឋបាល & អត្តសញ្ញាណកម្ម

សេវាអត្រានុកូលដ្ឋាន៖ ១,២១៧ ច្បាប់ (ក្នុងនោះចុះផ្តល់ដល់ផ្ទះជូនចាស់ជរា/ជនពិការ ៣៥៤ គ្រួសារ) អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ៥,១៤៩ នាក់ សៀវភៅគ្រួសារ & ស្នាក់នៅ ៩៧០ គ្រួសារ ក្នុងនោះផ្តល់លិខិតបញ្ជាក់ ១០,៦៤៦ ច្បាប់ ប្រមូលចំណូលសេវារដ្ឋបាល ២,៧៤៥,០០០ ៛





### ២.ការដោះស្រាយវិវាទ

ដោះស្រាយវិវាទ (ឈ្នះ-ឈ្នះ)៖ ២៥៦ ករណី (បញ្ជូនទៅថ្នាក់លើ ២២ ករណី)

**ការងារបរិស្ថាន** ចុះផ្សព្វផ្សាយ ផាកពិន័យ និងម្ចាស់ការតាមគោលដៅ។

មានវិធានការទប់ស្កាត់ និងរំលត់អគ្គិភ័យ ព្រមទាំងគ្រោះមហន្តរាយ

បានចុះផ្សព្វផ្សាយអប់រំការបង្ការអគ្គិភ័យ និងការប្រកាសអាសន្នគ្រោះធម្មជាតិបាន៖

- ចាត់តាំងកម្លាំងអន្តរាគមន៍សង្គ្រោះប្រជាពលរដ្ឋរងគ្រោះដោយទាន់ពេលវេលា។
- សហការ អន្តរាគមន៍ស្តារប្រព័ន្ធទឹក/ទ្វារទឹក ដើម្បីរំដោះទឹក និងផ្គត់ផ្គង់ទឹកស្រោចស្រពដំណាំជូនពលរដ្ឋ។



# ការចូលរួមរបស់ថ្នាក់ដឹកនាំ និងសប្បុរសជន










៩









# ស្លាដៃ និងជ័យលាភី ទទួលបានពីការខិតខំប្រឹងប្រែងបម្រើប្រជាពលរដ្ឋ និងការទទួលស្គាល់ពីថ្នាក់ដឹកនាំ

## ឆ្នាំ២០២៣-២០២៤ទទួលជ័យលាភីលេខ១ស្រុក,ខេត្ត, និងជាប់ជ័យលាភីក្រសួងទទួលបាន៩លានរៀល










១០

## ឆ្នាំ២០២២-២០២៥ ទទួលបានជ័យលាភីលេខ១ ថ្នាក់ខេត្ត ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព









# ៤. បទពិសោធល្អៗ ក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព

**អនុវត្តតាមយន្តការច្រកចេញចូលតែមួយ៖**

១. អនុវត្តតាមយន្តការច្រកចេញចូលតែមួយ៖ដោយស្នាមញញឹម រាក់ទាក់រួសរាយ

- ផ្តល់សេវារហ័ស ទាន់ពេលវេលា តម្លាភាព និងគុណភាព តាមតារាងតម្លៃកំណត់ ដោយលុបបំបាត់នូវបាតុភាពអសកម្មក្រៅផ្លូវការ។
- ផ្តល់សេវាចល័ត «ដល់ខ្នងផ្ទះ» ជូនចាស់ជរា និងជនពិការ និងតាមប្រព័ន្ធឌីជីថល (Telegram, QR Code..) ប្រអប់សំបុត្រស្ថាបនា ដើម្បីទទួល និងដោះស្រាយ សំណូមពរបានទាន់ពេលវេលា និងបង្កើតបាននូវកិត្យានុភាព ទំនុកចិត្តពីប្រជាពលរដ្ឋ។








១១

២. ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងកិច្ចសហការអភិវឌ្ឍន៍មូលដ្ឋាន

- មានសាមគ្គីភាពក្នុងគណៈបញ្ជាការឯកភាពឃុំ ដោយចុះអន្តរាគមន៍ដោះស្រាយបញ្ហាបន្ទាន់ភ្លាមៗ និងសម្របសម្រួលទំនាស់តាម «យុទ្ធសាស្ត្រឈ្នះ-ឈ្នះ» រក្សាបាននូវសន្តិសុខផ្លូវចិត្តជូនពលរដ្ឋ។
- ចុះជួបសួរសុខទុក្ខនិងស្តាប់កង្វល់ប្រជាពលរដ្ឋតាមភូមិជាប្រចាំ ដើម្បីដោះស្រាយបញ្ហាប្រឈមចំគោលដៅ។
- មានការចូលរួមពីថ្នាក់ដឹកនាំ ព្រះសង្ឃ និងសប្បុរសជន និងការឧបត្ថម្ភ គាំទ្រដល់ការអភិវឌ្ឍ និងសន្តិសុខមូលដ្ឋាន។



# ៥. បញ្ហាប្រឈម និងសំណូមពរ

## បញ្ហាប្រឈម

១. អនុវត្តច្បាប់និងអប់រំកែប្រែពេលដែលពួកគាត់ចេញពីពន្ធនាគារ ឬមណ្ឌលកែប្រែវិញមួយចំនួន នៅតែធ្វើសកម្មភាពដដែល។

២. ពិបាកក្នុងការគ្រប់គ្រងប្រជាពលរដ្ឋបណ្ដោះអាសន្ន លំហូរនៃពលករចំណាកស្រុក និងការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋ។

៣. មិនទាន់មានទ្វារទឹក ខ្វះទឹកសម្រាប់ធ្វើស្រែបង្កបង្កើនផល







## សំណូមពរ

១. ស្នើសុំកម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំបន្ថែម និងបើកវគ្គបណ្ដុះ-បណ្ដាលជំនាញព័ត៌មានវិទ្យា។

២. បំពាក់ឧបករណ៍ឌីជីថលទំនើបៗ និងបើកវគ្គបំប៉នខ្លីៗដល់មន្ត្រីឃុំ ដើម្បីបម្រើសេវាឱ្យបានលឿន។

៣. សូមអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹងនៅតាមច្រកព្រំដែន និងអ្នកដែលប្រព្រឹត្តបទល្មើស។

៤. ជួយឧបត្ថម្ភថវិកា និងគាំទ្រគ្រឿងបរិក្ខារបច្ចេកវិទ្យាជូនកម្លាំងប្រជាការពារ។

៥. ស្នើសុំក្រសួងធនធានទឹកពន្លឿនការសាងសង់ទ្វារទឹកដែលធ្លាប់មានកាលពីមុន ស្តារប្រឡាយអូរខ្សាច់សម្រាប់បិទបើកទ្វាទឹកប្រើប្រាស់ក្នុងរដូវវស្សា ។

រដ្ឋបាលឃុំដំណាក់អំពិល

# សូមអរគុណ